**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាសកម្មភាពជនពិការ**

**លេខ:** ០០១.កសជ.ប្រក

# ប្រកាស

# ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅ

## នៃក្រុមការងារសកម្មភាពជនពិការ នៅតាមក្រសួង ស្ថាប័ន

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## និងជាប្រធានក្រុមប្រឹក្សាសកម្មភាពជនពិការ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩១២/០០៧ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការ

**ប្រការ ១.-**

ប្រកាសនេះ កំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រុមការងារសកម្មភាពជនពិការនៅតាមក្រសួង ស្ថាប័ន ដែលសរសេរជាអក្សរកាត់ថា **ក.ស.ជ.ក.ស**. ជាយន្តការសម្របសម្រួល និងពិគ្រោះយោបល់លើបញ្ហាពិការភាពនៅក្នុងក្របខណ្ឌក្រសួង ស្ថាប័ននីមួយៗ។

**ប្រការ ២.-**

សមាសភាព **ក.ស.ជ.ក.ស**. រួមមាន៖

- រដ្ឋមន្ត្រី ឬប្រធានស្ថាប័ន ប្រធានកិត្តិយស
- សមាជិកក្រុមប្រឹក្សាសកម្មភាពជនពិការក្នុងក្រសួង ស្ថាប័នសាមី ប្រធាន
- ករណីក្រសួង ស្ថាប័ន ដែលមិនមែនជាសមាជិកក្រុមប្រឹក្សាសកម្មភាពជនពិការ រដ្ឋមន្ត្រី ឬប្រធានស្ថាប័ននោះ អាចចាត់អនុរដ្ឋលេខាធិការមួយរូបជាប្រធាន
- អគ្គនាយក ឬឋានៈប្រហាក់ប្រហែល ១រូប អនុប្រធាន
- ប្រធាននាយកដ្ឋាន/ឋានៈប្រហាក់ប្រហែល មួយចំនួន សមាជិក
- មន្ត្រីដែលជាជនពិការ មួយចំនួន សមាជិក
- លេខាធិការនៃលេខាធិការដ្ឋាន **ក.ស.ជ.ក.ស**. សមាជិកអចិន្ត្រៃយ៍។

សមាសភាពជាក់ស្តែងរបស់ **ក.ស.ជ.ក.ស**. ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី។

**ប្រការ ៣.-**

**ក.ស.ជ.ក.ស**. មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ផ្តល់ការពិគ្រោះយោបល់ជំនាញលើបញ្ហាពិការភាព និងការស្តារលទ្ធភាពពលកម្មនៅក្នុងក្រសួង ស្ថាប័ន
- ជួយរៀបចំគោលនយោបាយ ផែនការជាតិ និងយុទ្ធសាស្ត្រដែលមានការពាក់ព័ន្ធទៅនឹងពិការភាព និងការស្តារលទ្ធភាពពលកម្មនៅក្នុងក្រសួង ស្ថាប័ន
- ជួយជំរុញការអនុវត្តគោលនយោបាយ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធទៅនឹងបញ្ហាពិការភាព និងការស្តារលទ្ធភាពពលកម្មនៅក្នុងក្រសួង ស្ថាប័ន
- លើកសំណើជូនក្រុមប្រឹក្សាសកម្មភាពជនពិការ ដើម្បីកែសម្រួល បំពេញបន្ថែម ធ្វើវិសោធនកម្មគោលនយោបាយ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធទៅនឹងបញ្ហាពិការភាព
- តាមដាន វាយតម្លៃការអនុវត្តគោលនយោបាយ ផែនការជាតិ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធទៅនឹងបញ្ហាពិការភាពនៅក្នុងក្រសួង ស្ថាប័ន
- ទំនាក់ទំនងជាមួយសហគមន៍ជាតិ អន្តរជាតិ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ កៀរគរប្រភពធនធានទាំងក្នុងនិងក្រៅប្រទេស
- ចូលរួម និងរៀបចំទិវាជនពិការជាតិ ទិវាជនពិការអន្តរជាតិ និងទិវាជនពិការផ្សេងៗទៀតនៅក្នុងក្រសួង ស្ថាប័ន
- ជួយក្រុមប្រឹក្សាសកម្មភាពជនពិការ ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាពទាក់ទងពិការភាព និងទទួលយកទៅអនុវត្ត

- ដឹកនាំ ចាត់ចែង អនុវត្ត និងធ្វើរបាយការណ៍បូកសរុបលើការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ នៅក្នុងក្រសួង ស្ថាប័ន
- រៀបចំរបាយការណ៍ស្តីពីស្ថានភាពជនពិការនៅក្នុងក្រសួង ស្ថាប័នជូនក្រុមប្រឹក្សាសកម្មភាពជនពិការ
- បំពេញភារកិច្ចផ្សេងទៀតដែលក្រុមប្រឹក្សាសកម្មភាពជនពិការប្រគល់ជូន។

**ប្រការ ៤.-**

**ក.ស.ជ.ក.ស.** ត្រូវធ្វើការប្រជុំយ៉ាងតិច២ (ពីរ)ដង ក្នុង១ (មួយ)ឆ្នាំ។ ក្នុងករណីចាំបាច់ **ក.ស.ជ.ក.ស.** អាចធ្វើការប្រជុំវិសាមញ្ញបានតាមការអញ្ជើញរបស់ប្រធាន **ក.ស.ជ.ក.ស.** ។

**ក.ស.ជ.ក.ស.** ត្រូវធ្វើការបូកសរុបរបាយការណ៍ប្រចាំឆ្នាំអំពីលទ្ធផល នៃការអនុវត្តសកម្មភាពការងារ និងអនុសាសន៍ដែល **ក.ស.ជ.ក.ស.** ដាក់ជូនក្រុមប្រឹក្សាសកម្មភាពជនពិការ។

ប្រធាន **ក.ស.ជ.ក.ស.** ជាប្រធាននៃរាល់កិច្ចប្រជុំ។ ប្រសិនបើប្រធានអវត្តមាន ប្រធានត្រូវផ្ទេរសិទ្ធិជូនអនុប្រធាន។

**ក.ស.ជ.ក.ស.** អាចអញ្ជើញអ្នកជំនាញពាក់ព័ន្ធឲ្យចូលរួមក្នុងអង្គប្រជុំបាន។

**ប្រការ ៥.-**

**ក.ស.ជ.ក.ស.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័ននានា តំណាងអង្គការមិនមែនរដ្ឋាភិបាល តំណាងជនពិការដែលជាជនពិការ ដៃគូអភិវឌ្ឍ និងផ្នែកឯកជន ដើម្បីចូលរួមប្រជុំផ្តល់យោបល់ ឬធ្វើជាអ្នកសង្កេតការណ៍តាមការចាំបាច់។

**ប្រការ ៦.-**

របៀបរបបនៃការប្រជុំរបស់ **ក.ស.ជ.ក.ស.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ **ក.ស.ជ.ក.ស.**។

**ប្រការ ៧.-**

**ក.ស.ជ.ក.ស.** មានសិទ្ធិប្រើត្រាដោយឡែករបស់ខ្លួនដើម្បីបំពេញការងារ។

**ប្រការ ៨.-**

**ក.ស.ជ.ក.ស.** មានលេខាធិការដ្ឋានមួយជាអង្គភាពប្រតិបត្តិ ដែលមានទីតាំងនៅក្នុងក្រសួង ស្ថាប័នសាមុី។

**ប្រការ ៩.-**

លេខាធិការដ្ឋាន **ក.ស.ជ.ក.ស.** ដឹកនាំដោយលេខាធិការមួយរូបនិងមានលេខាធិការរងមួយចំនួនតាមការចាំបាច់ ដែលតែងតាំងដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមុី។

លេខាធិការដ្ឋាន **ក.ស.ជ.ក.ស.** មានមន្ត្រីបម្រើការងារមកពីក្របខ័ណ្ឌមុខងារសាធារណៈដែលមានស្រាប់របស់ក្រសួង ស្ថាប័នសាមុី និងអាចប្រើមន្ត្រីជាប់កិច្ចសន្យា និងជំនួយការ អ្នកជំនាញការជាតិនិងអន្តរជាតិមួយចំនួនតាមការចាំបាច់។

**ប្រការ ១០.-**

លេខាធិការដ្ឋាន **ក.ស.ជ.ក.ស.** មានតួនាទីនិងភារកិច្ចជាសេនាធិការជួយដល់ដំណើការតួនាទីនិងភារកិច្ចរបស់ **ក.ស.ជ.ក.ស.** ។

**ប្រការ ១១.-**

ការចំណាយសម្រាប់ដំណើរការរបស់ **ក.ស.ជ.ក.ស.** ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងថវិការបស់ក្រសួង ស្ថាប័នសាម៉ី ។

**ក.ស.ជ.ក.ស.** មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវមូលនិធិបដិភាគដែលបានមកពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

**ប្រការ ១២.-**

ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៩ ខែ ឧសភា ឆ្នាំ២០១៤

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**និងជាប្រធានក្រុមប្រឹក្សាសកម្មភាពជនពិការ**

**វង សូត**

**ចម្លងជូន** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សមាជិកក្រុមប្រឹក្សាសកម្មភាពជនពិការ
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ